# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៩៥/១៣-តេ យុង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ សុខ ម៉ាធឿង

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន តេ យុង (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិបុរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៨៣០ ៩០១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក ជូ ចាន់ស៊ក ទីប្រឹក្សាក្រុមហ៊ុន
២- លោក ព្រាប ឡេន ប្រធានរដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ -**សម្ព័ន្ធសហជីពកម្ពុជា**
-**សហជីពកម្ពុជានៃរោងចក្រកាត់ដេរ តេយុង ខេមបូឌា**
អាសយដ្ឋាន ៖ ភូមិត្របុរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៨៩ ៩៣ ០២ ០៤ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖

១- លោក ឈុន សំអួន មន្ត្រីសម្ព័ន្ធសហជីពកម្ពុជា


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- កញ្ញា ព្រំ ចិន្ដា ប្រធានសហជីពកម្ពុជា នៃរោងចក្រកាត់ដេរ តេយុង

៣- កញ្ញា ម៉ៅ ស្រីមុំ អនុប្រធានសហជីពកម្ពុជា នៃរោងចក្រកាត់ដេរ តេយុង

៤- កញ្ញា ទ្រំ កក្កដា លេខាធិការសហជីពកម្ពុជា នៃរោងចក្រកាត់ដេរ តេយុង

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីកម្មករសុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់លើកទឹកចិត្ត ក្នុងម្នាក់ចំនួន ៣ ដុល្លារ (បីដុល្លារ) សម្រាប់ខែមករា ២០១៣ នៅពេលកម្មករចេញម៉ោង ១៦៖០០ ល្ងាច។ ភាគីក្រុមហ៊ុនមិនឯកភាពផ្ដល់ជូនទេ ដោយសារក្រុមហ៊ុនមានលក្ខខណ្ឌធ្លាប់បានអនុវត្តកន្លងមក គឺកម្មករណាចេញម៉ោង ១៦៖០០ មិនត្រូវផ្ដល់ប្រាក់លើកទឹកចិត្ត ចំនួន ៣ ដុល្លារ (បីដុល្លារ) ជូនឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ១៥៥/១៣ កប/កណ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ (វេលាម៉ោង ២ និង ០០នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានទទួលពាក្យបណ្ដឹងរបស់សម្ព័ន្ធសហជីពកម្ពុជា ស្ដីពីការទាមទារឱ្យនិយោជកផ្ដល់ប្រាក់លើកទឹកចិត្តដល់កម្មករនិយោជិត ក្នុងម្នាក់ចំនួន ០៣ ដុល្លារអាមេរិក សម្រាប់ខែមករា ឆ្នាំ២០១៣ នៅពេលកម្មករចេញពីធ្វើការនៅម៉ោង ៤៖០០ ល្ងាច ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាលបានចាត់តាំងមន្ត្រីជំនាញ

THE ARBITRATION COUNCIL

ធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សា នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៩៥/១៣ កប/កណ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ ដោយសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃ ទី២០ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ០២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីផលប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នាឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេចដែលជាប់កាតព្វកិច្ច តាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីផលប្រយោជន៍។

ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លើចំណុចវិវាទអំពីផលប្រយោជន៍នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ របស់នាយកក្រុមហ៊ុន តេ យ៉ុង ខេមបូឌា ខូអិលធីឌី

គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអជ្ញាកណ្តាល ស្តីពីការផ្ទេរសិទ្ធិជូនលោក ព្រាប ឡេន និង លោក ជូ ចាន់ស័ក។

២- លិខិតលេខ ១១៦៦ ក.ប/អក/វក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ របស់នាយកដ្ឋានវិវាទការងារ ជម្រាបជូន លោកនាយកក្រុមហ៊ុន TAE YOUNG (CAMBODIA) CO., LTD ស្តីពីការជូនដំណឹងអំពីការដាក់ពាក្យស្នើសុំភាពជាតំណាងបំផុត របស់សហជីពកម្មករកម្ពុជារោងចក្រ TAE YOUNG (CAMBODIA) CO., LTD ។

៣- លិខិតរបស់គណៈកម្មការសហជីពកម្មករកម្ពុជារោងចក្រ TAE YOUNG (CAMBODIA) CO., LTD គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២។

៤- កិច្ចព្រមព្រៀងរវាងសហព័ន្ធសហជីពកម្មករកម្ពុជា សហជីពកម្មករកម្ពុជា និងរោងចក្រ តេយ៉ុង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ០៤៤/១៣ ក.ប ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្ពុជានៃរោងចក្រកាត់ដេរ តេយ៉ុង ខេមបូឌា ជាអង្គការវិជ្ជាជីវៈមួយ របស់កម្មករនិយោជិត ត្រូវបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពេញលក្ខណៈច្បាប់ ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្ពុជានៃរោងចក្រកាត់ដេរ តេយ៉ុង ខេមបូឌា បានចុះបញ្ជិកាលេខ ២៧៧៦ ក.ប/វក. ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣។

៣- លក្ខន្តិកៈសហជីពកម្ពុជានៃរោងចក្រកាត់ដេរ តេយ៉ុង ខេមបូឌា បានចុះបញ្ជិកាលេខ ២៧៧៦ ក.ប/វក. ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន តេ យ៉ុង លេខ ១៥៥/១៣ កប/កណ ចុះថ្ងៃ ទី០៦ ខែមីនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន តេ យ៉ុង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៩៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៩៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។

៣- កិច្ចព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន តេ យុង (ខេមបូឌា) គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតប្រហែលប្រមាណ ៧៨០ នាក់។
- សហជីពកម្ពុជានៃរោងចក្រកាត់ដេរ តេយុង ខេមបូឌា គឺជាដើមបណ្តឹងនៃសំណុំរឿងនេះ។ សហជីពនេះមានសមាជិកចំនួនប្រហែល ៣០០ នាក់ និងទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាលេខ ២៧៧៦ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣។ សហជីពកម្មករកម្ពុជាជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុននេះ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តក្នុងម្នាក់ចំនួន ០៣ ដុល្លារអាមេរិក សម្រាប់ខែមករា ឆ្នាំ ២០១៣ នៅពេលកម្មករនិយោជិតចេញម៉ោង ០៤៖០០ រសៀល**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារអាមេរិកដល់កម្មករនិយោជិតប្រហែល ៦០០ នាក់ ដែលបានចេញពីធ្វើការនៅម៉ោង ០៤៖០០ រសៀល ដោយមិនបានធ្វើការបន្ថែមម៉ោងរហូតដល់ម៉ោង ០៦៖០០ យប់ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣។ ភាគីកម្មករ និយោជិតលើកឡើងអំពីមូលហេតុថា និយោជកទើបនឹងអនុវត្តការផ្តល់ប្រាក់លើកទឹកចិត្តនេះបានមួយខែទេ ហើយកម្មករនិយោជិតចង់ជិះឡានទៅផ្ទះជាមួយនឹងកម្មកររបស់រោងចក្រដទៃទៀត ដែលចេញពីធ្វើការនៅម៉ោង ០៤៖០០ រសៀលដែរ។ ម្យ៉ាងវិញទៀត ភាគីកម្មករនិយោជិតយល់ឃើញថា ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៣ គឺជាថ្ងៃពិសេស ដោយសារថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ គឺជាថ្ងៃដង្ហែព្រះបរមសពព្រះករុណាព្រះបរមរតនកោដ្ឋ ។
- ភាគីនិយោជកលើកឡើងថា ទាក់ទងនឹងចំណុចនេះ និយោជកមិនអាចផ្តល់ជូនបានទេ ដោយសារមានកិច្ចព្រមព្រៀងចែងថា ប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារអាមេរិកប្រចាំខែនេះ គឺជាប្រាក់មានភ្ជាប់លក្ខខណ្ឌដែលតម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងរាល់ថ្ងៃណា ដែលមានការបន្ថែមម៉ោង ចាប់ពីម៉ោង ០៤៖០០ រសៀល ដល់ម៉ោង ០៦៖០០ យប់។ ភាគីនិយោជកបញ្ជាក់ថា និយោជកមិនចាំចំនួនកម្មករនិយោជិត ដែលនិយោជកមិនបានផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ខែមករានេះទេ។
- ភាគីទាំងពីរមានវិវាទចំពោះតែលក្ខខណ្ឌនៃការធ្វើការបន្ថែមម៉ោងប៉ុណ្ណោះ។

THE ARBITRATION COUNCIL

- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ចែងថា "*៣-ក្រុមហ៊ុនឯកភាពផ្តល់ប្រាក់ធ្វើការទៀងទាត់ដល់កម្មករ-កម្មការិនីចំនួន ០៣ ដុល្លារអាមេរិក សម្រាប់លើកទឹកចិត្តដល់កម្មករ-កម្មការិនី ដែលបានធ្វើការពេញរយៈពេលមួយខែ ដោយមិនមានអវត្តមាន និងជួយធ្វើការបន្ថែមម៉ោងពេញរយៈពេលមួយខែ ដោយគិតចាប់ពីម៉ោង៤ រហូតដល់ម៉ោង ៦ល្ងាច លើកលែងតែក្នុងករណីដែលក្រុមហ៊ុនបានអនុញ្ញាត ។*
- ភាគីនិយោជកបញ្ជាក់ថា និយោជកបានប្រជុំប្រាប់ប្រធានក្រុម និងសហជីពឱ្យជួយផ្សព្វផ្សាយអំពីគោលការណ៍ និងលក្ខខណ្ឌ ក្នុងការផ្ដល់ប្រាក់លើកទឹកចិត្តនេះឱ្យកម្មករនិយោជិតដឹងផងដែរ ។
- ភាគីកម្មករនិយោជិតទទួលស្គាល់ថា ខ្លួនបានទទួលដំណឹងតាមរយៈប្រធានក្រុមនៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៣ ថា ចាប់ពីថ្ងៃនេះទៅ ប្រសិនកម្មករណាចេញពីធ្វើការនៅម៉ោង ០៤៖០០ រសៀល ពួកគេនឹងមិនទទួលបានប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារអាមេរិកនេះទេ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ខ្លួនបានស្នើសុំទៅនិយោជក ចំនួន ០២ ដង ឱ្យកម្មករចេញនៅម៉ោង ០៤៖០០ ល្ងាច ដោយមិនមានការកាត់ប្រាក់រង្វាន់ខាងលើនេះ ។
- ភាគីនិយោជកទទួលស្គាល់ថា ភាគីកម្មករនិយោជិតពិតជាបានធ្វើការស្នើសុំមែន ក៏ប៉ុន្តែនិយោជកក៏បានបដិសេធសំណើរបស់ពួកគេផងដែរ ។
- ជាចុងក្រោយ ភាគីនិយោជកនៅតែប្រកាន់ជំហរមិនផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិត ដោយសារតែប្រាក់លើកទឹកចិត្តនេះ គឺជាប្រាក់ដែលមានភ្ជាប់លក្ខខណ្ឌ ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

មុននឹងពិចារណាចំណុចទាមទារទាំងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការបកស្រាយអំពីវិវាទអំពីសិទ្ធិ និងវិវាទអំពីផលប្រយោជន៍ជាមុនសិន ។

មាត្រា ៣១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តន៍បញ្ញត្តិច្បាប់ ឬអនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះ ដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់*" ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ "*សេចក្តីបង្គាប់អាជ្ញាកណ្ដាល ដែលដោះស្រាយវិវាទផលប្រយោជន៍នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ*" ។

មាត្រា ៣១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ និងប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ខាងលើ បានបញ្ជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវដោះស្រាយជាផ្លូវច្បាប់ ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬអនុសញ្ញារួម ។ ចំពោះវិវាទក្រៅពីនេះ គឺអាជ្ញាកណ្ដាលត្រូវដោះស្រាយដោយសមធម៌ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសន្និដ្ឋាន

THE ARBITRATION COUNCIL

ថា វិវាទដែលទាក់ទងនឹងការបកស្រាយច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយ គឺជាវិវាទអំពីសិទ្ធិ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទអំពីសិទ្ធិតាមផ្លូវច្បាប់។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និងទី៥, លេខ ១៣/១១-ហ្គោលកាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និងទី២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)*។ រីឯវិវាទដែលមិនមានចែងក្នុងច្បាប់ មិនមានកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយ គឺជាវិវាទអំពីផលប្រយោជន៍ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទអំពីផលប្រយោជន៍តាមផ្លូវសមធម៌។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣១/១១-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ហេតុផលចំណុចវិវាទទី៤ និងលេខ ៦២/១១-អូសេអង់ ហេតុផលចំណុចវិវាទទី១)*។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តក្នុងម្នាក់ចំនួន ០៣ ដុល្លារអាមេរិក សម្រាប់ខែមករា ឆ្នាំ ២០១៣ នៅពេលកម្មករនិយោជិតចេញម៉ោង ០៤៖០០ រសៀល**

ជាបឋម ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើការទាមទារក្នុងចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិ ឬអំពីផលប្រយោជន៍?

ដោយសារការទាមទារនេះមានចែងនៅក្នុងចំណុចទី ៣ នៃកិច្ចព្រមព្រៀងចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលធ្វើឡើងរវាងសហព័ន្ធសហជីពកម្មករកម្ពុជា សហជីពកម្មករកម្ពុជា និងរោងចក្រ តេយ៉ុង ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះជាវិវាទអំពីសិទ្ធិ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតធ្វើការទាមទារចំណុចនេះ ដោយសារខ្លួនចង់ជិះឡានទៅផ្ទះជាមួយកម្មកររបស់រោងចក្រដទៃនៅម៉ោង ០៤៖០០ រសៀល ហើយកម្មករនិយោជិតយល់ឃើញថា ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ គឺជាថ្ងៃពិសេស ដោយសារថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ គឺជាថ្ងៃដង្ហែព្រះបរមសពព្រះករុណាព្រះបរមរតនកោដ្ឋ។ ភាគីនិយោជកបដិសេធមិនផ្តល់ជូនតាមការទាមទារ ដោយមូលហេតុថា ប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារ អាមេរិកនេះ គឺជាប្រាក់ដែលមានភ្ជាប់លក្ខខណ្ឌទៅនឹងការធ្វើការថែមម៉ោង។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើភាគីកម្មករនិយោជិតមានសិទ្ធិទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារ អាមេរិក ដែលមានភ្ជាប់លក្ខខណ្ឌទៅនឹងការធ្វើការថែមម៉ោង សម្រាប់ខែមករា ឆ្នាំ២០១៣ ដែរ ឬទេ?

ចំណុចទី ៣ នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលធ្វើឡើងរវាងសហព័ន្ធសហជីពកម្មករកម្ពុជា សហជីពកម្មករកម្ពុជា និងរោងចក្រ តេយ៉ុង ចែងថា *"៣-ក្រុមហ៊ុនឯកភាពផ្តល់ប្រាក់ធ្វើការ ទៀងទាត់ដល់កម្មករ-កម្មការិនីចំនួន ០៣ ដុល្លារអាមេរិក សម្រាប់លើកទឹកចិត្តដល់កម្មករ-កម្មការិនី ដែលបានធ្វើការពេញរយៈពេលមួយខែ ដោយមិនមានអវត្តមាន និងជួយធ្វើការបន្ថែមម៉ោងពេញរយៈពេលមួយខែដោយ គិតចាប់ពីម៉ោង ៤ រហូតដល់ម៉ោង ៦ល្ងាច លើកលែងតែក្នុងករណីដែលក្រុមហ៊ុនបានអនុញ្ញាត។*

តាមរយៈអង្គហេតុ និយោជកបានចុះកិច្ចព្រមព្រៀងជាមួយសហជីពកម្មករកម្ពុជា ដែលជាសហជីពមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ ដើម្បីផ្តល់ប្រាក់លើកទឹកចិត្តចំនួន ៣ ដុល្លារអាមេរិក សម្រាប់លើកទឹកចិត្តដល់កម្មករ-កម្មការិនី ដែលបានធ្វើការពេញរយៈពេលមួយខែ ដោយមិនមានអវត្តមាន និងជួយធ្វើការបន្ថែមម៉ោងពេញ

THE ARBITRATION COUNCIL

រយៈពេលមួយខែ ដោយគិតចាប់ពីម៉ោង ៤ រហូតដល់ម៉ោង ៦ ល្ងាច។ ទន្ទឹមនឹងនេះផងដែរ និយោជកក៏បានប្រាប់ប្រធានក្រុមឱ្យជួយផ្សព្វផ្សាយអំពីលក្ខខណ្ឌ ក្នុងការទទួលបានប្រាក់លើកទឹកចិត្តនេះដល់កម្មករផងដែរ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានទទួលស្គាល់ថា កម្មករបានដឹងអំពីលក្ខខណ្ឌក្នុងការទទួលបានប្រាក់លើកទឹកចិត្តនេះ តាមរយៈប្រធានក្រុម។ ពោលគឺលុះត្រាតែធ្វើការបន្ថែមម៉ោង ចាប់ពីម៉ោង ០៤៖០០ រសៀលដល់ម៉ោង ០៦៖០០ ល្ងាច ទើបអាចទទួលបានប្រាក់លើកទឹកចិត្តនេះ។

តាមរយៈកិច្ចព្រមព្រៀងខាងលើ ភាគីនិយោជកនៅតែប្រកាន់ជំហរមិនផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិត ដោយសារប្រាក់រង្វាន់លើកទឹកចិត្តនេះ គឺជាប្រាក់រង្វាន់ដោយមានភ្ជាប់លក្ខខណ្ឌទៅនឹងការធ្វើការបន្ថែមម៉ោងចាប់ពី ម៉ោង ០៤៖០០ រសៀល រហូតដល់ម៉ោង ០៦៖០០ ល្ងាច។ នៅក្នុងករណីនេះ កម្មករនិយោជិតមិនបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងទេ។ ដូចនេះ កម្មករនិយោជិតមិនមានសិទ្ធិទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តចំនួន ០៣ ដុល្លារអាមេរិកសម្រាប់ខែមករាទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តក្នុងម្នាក់ចំនួន ០៣ ដុល្លារអាមេរិក សម្រាប់ខែមករា ឆ្នាំ២០១៣ នៅពេលកម្មករនិយោជិតចេញពីធ្វើការនៅម៉ោង ០៤៖០០ រសៀល ដោយមិនបានធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ០៤៖០០ រសៀល រហូតដល់ម៉ោង ០៦៖០០ ល្ងាច យោងតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

ចំណុចវិវាទ ៖

បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តក្នុងម្នាក់ចំនួន ០៣ ដុល្លារអាមេរិក សម្រាប់ខែមករា ឆ្នាំ២០១៣ នៅពេលកម្មករនិយោជិតចេញពីធ្វើការនៅម៉ោង ០៤៖០០ រសៀល ដោយមិនបានធ្វើការបន្ថែមម៉ោង ចាប់ពីម៉ោង ០៤៖០០ រសៀល រហូតដល់ម៉ោង ០៦៖០០ ល្ងាច យោងតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣។

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាមហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២។

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន**

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណន**

ហត្ថលេខា ៖ ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **សុខ ម៉ាឡឿង**

ហត្ថលេខា ៖ ----------------------------------------